ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

istry of Industry, Mines and Energy

លេខ : [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០០៨

# អាជ្ញាប័ណ្ណស្វែងរុករក

( លើកទី២ )

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មរ៉ែដែក នៅតំបន់ស្រុករវៀង ខេត្តព្រះវិហារ រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៦ ។
- បានឃើញសេចក្តីកែតម្រូវលេខ:០០១ ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០០៨ នៃកិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មរ៉ែដែក នៅតំបន់ស្រុករវៀង ខេត្តព្រះវិហារ រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៦ ។

## សំរេច

**ប្រការ១:** អនុញ្ញាតអោយក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group មានអាសយដ្ឋាននៅផ្ទះលេខ:៥៦ ផ្លូវលេខ:៥១ រាជធានីភ្នំពេញ បន្តធ្វើការសិក្សាស្រាវជ្រាវរ៉ែដែក

នៅតំបន់ស្រុករវៀង ខេត្តព្រះវិហារ លើផ្ទៃដីទំហំ ១៣០៦.៧៤ (មួយពាន់បីរយប្រាំមួយក្បៀសចិតសិបបួន) គីឡូម៉ែត្រក្រឡា (ដោយមិនគិតបញ្ចូលតំបន់ភ្នំថ្មទំហំ ៣.៧៥ ដែលជាតំបន់សម្បទានរបស់ក្រុមហ៊ុន Ratanak Stone Cambodia Development Co., Ltd ដែលឋិតនៅក្នុងតំបន់ស្រុករវៀង ខេត្តព្រះវិហារ) ដែលមានកូអរដោណេដូចតទៅ :

| ចំណុច | អាប់ស៊ីស | អរដោណេ | ចំណុច | អាប់ស៊ីស | អរដោណេ |
|---|---|---|---|---|---|
| A | 5 09 000 | 15 07 100 | W | 5 54 000 | 14 81 100 |
| B | 5 15 200 | 15 07 100 | X | 5 48 500 | 14 81 100 |
| C | 5 15 200 | 15 05 000 | Y | 5 48 500 | 14 78 000 |
| D | 5 16 700 | 15 05 000 | Z | 5 41 500 | 14 78 000 |
| E | 5 16 700 | 15 02 000 | A1 | 5 41 500 | 14 75 000 |
| F | 5 19 500 | 15 02 000 | B1 | 5 38 000 | 14 75 000 |
| G | 5 19 500 | 14 99 000 | C1 | 5 38 000 | 14 72 000 |
| H | 5 21 400 | 14 99 000 | D1 | 5 35 000 | 14 72 000 |
| I | 5 21 400 | 14 96 000 | E1 | 5 35 000 | 14 68 000 |
| J | 5 24 000 | 14 96 000 | F 1 | 5 31 500 | 14 68 000 |
| K | 5 24 000 | 14 92 000 | G 1 | 5 31 500 | 14 64 000 |
| L | 5 17 000 | 14 92 000 | H1 | 5 24 000 | 14 64 000 |
| M | 5 17 000 | 14 88 000 | I1 | 5 24 000 | 14 60 000 |
| N | 5 28 350 | 14 88 000 | J1 | 5 19 500 | 14 60 000 |
| O | 5 28 350 | 14 86 600 | K1 | 5 19 500 | 14 54 000 |
| P | 5 32 000 | 14 86 600 | L1 | 5 14 500 | 14 54 000 |
| Q | 5 32 000 | 14 87 300 | M1 | 5 14 500 | 14 50 000 |
| R | 5 34 200 | 14 87 300 | N1 | 5 06 000 | 14 50 000 |
| S | 5 34 200 | 14 88 300 | O1 | 5 06 000 | 14 95 000 |
| T | 5 59 100 | 14 88 300 | P1 | 5 08 000 | 14 95 000 |
| U | 5 59 100 | 14 84 000 | Q1 | 5 08000 | 14 96 000 |
| V | 5 54 000 | 14 84 000 | R1 | 5 09 000 | 14 96 000 |

**ប្រការ២:** ក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group ត្រូវដំណើរការសិក្សាស្រាវជ្រាវរ៉ែដែកលើផ្ទៃដីដែលបានកំណត់ខាងលើ ដោយអនុវត្តទៅតាមផែនការឆ្នាំ និងកម្មវិធីការងាររបស់ខ្លួន ដោយធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសក្នុងការសិក្សាស្រាវជ្រាវរុករករ៉ែដែក ។

**ប្រការ៣:** អាជ្ញាប័ណ្ណនេះមានសុពលភាពរយៈពេល០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ។ មុនផុតកំណត់ ៣០ថ្ងៃ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវរ៉ែដែកបន្តជាថ្មី ។

**ប្រការ៤:** ក្នុងករណីប្រព្រឹត្តល្មើសលើល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០០៨ អាជ្ញាប័ណ្ណនេះ នឹងត្រូវដកហូត ឬត្រូវពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

**ប្រការ៥:** អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តព្រះវិហារ និង ប្រធានក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះ តាមភារៈកិច្ចរៀង១ខ្លួន ។

**ប្រការ៦:** អាជ្ញាប័ណ្ណនេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃ០៦ ខែតុលា ឆ្នាំ២០០៦ ។

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាលាខេត្តព្រះវិហារ
- សាលាស្រុករវៀង
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ស៊ុយ_សែម